## ៣ សញ្ញាសម្គាល់សម្រាប់ជ័យលាភី ថ្នាក់បណ្ឌិត

### ក- រូបសញ្ញា




### ខ- សញ្ញាសម្គាល់សម្រាប់ជ័យលាភីថ្នាក់បណ្ឌិត

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរូបរាងជាផ្កាឈូកក្រពុំ រំលេចទៅដោយសន្លឹកក្បាច់អង្គរពន្ធខាងក្រៅពណ៌មាស ទំហំកម្ពស់២៥ម.ម. និងទទឹង១៦ម.ម.

- ផ្នែកខាងលើមានមកុដរាជបញ្ចេញពន្លឺរង្សីពណ៌មាសចំនួន២៥និងមាន សញ្ញាឱមពណ៌មាសនៅខាងក្រោម
- ផ្នែកខាងក្នុងចំកណ្តាលមានកងចក្រពណ៌មាសចំនួន២៥ ដែលរំលេចទៅដោយរូបរាជសីហ៍ពណ៌មាសចំនួនពីរ ឈរអមព្រះខ័នរាជពណ៌មាសទ្រដោយក្បាច់ភ្ញីអង្គរនៅចំកណ្តាល។ រីឯនៅខាងក្រោមកងចក្រ រំលេចដោយក្រណាត់បូ ពណ៌ក្រហម ខៀវ ហើយក្នុងផ្ទៃបូមានសរសេរពាក្យថា **«បណ្ឌិត-DOCTOR'S DEGREE»** ពណ៌មាស ដែលទ្រដោយក្បាច់ភ្ញីអង្គរនៅបាតខាងក្រោម។

**១.២- អត្ថន័យ**

- **ក្បាច់អង្គរពទ្ធជុំវិញ** តំណាងឱ្យនិមិត្តរូបនៃវប្បធម៌ដ៏រុងរឿងខ្ពស់ត្រដែតនាសម័យអង្គរ ប្រកបដោយសុខសន្តិភាពនិងការអភិវឌ្ឍ
- **ពន្លឺឆព្វណ្ណរង្សី** ស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី
- **មកុដរាជ** តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រនិងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **សញ្ញាឱម** តំណាងឱ្យអំណាចកំពូលដែលមានការគាំទ្រពីថ្នាក់ក្រោមនិងប្រជារាស្ត្រ
- **កងចក្រ** តំណាងឱ្យប្រសិទ្ធភាព អំណាច និងសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចថែរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមទូទាំង២៥រាជធានី ខេត្ត
- **ព្រះខ័នរាជ្យ** តំណាងឱ្យអំណាច អាជ្ញាសឹក និងការដឹកនាំបញ្ជា ក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមជូនជាតិមាតុភូមិ
- **រាជសីហ៍** តំណាងឱ្យអំណាច មហិទ្ធប្ញទ្ធិនៃកងកម្លាំងនគរបាលជាតិក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **បូពណ៌ខៀវ** និង **ក្រហម** រំលេចគោរមងារ **បណ្ឌិត-DOCTOR'S DEGREE** ពណ៌មាសនៅចំកណ្តាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន ការប្តេជ្ញាចិត្ត ហ៊ានធ្វើពលិកម្ម និងតស៊ូ ប្រយុទ្ធរបស់កងកម្លាំងនគរបាលជាតិក្នុងការបម្រើជាតិនិងប្រជាពលរដ្ឋ
- **ពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តមសេចក្តីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា
- អក្សរ **បណ្ឌិត-DOCTOR'S DEGREE** ជាឈ្មោះនៃកម្រិតសញ្ញាបត្រខ្ពស់ជាងគេបង្អស់ ដែលបណ្ឌិត្យសភានគរបាលកម្ពុជាធ្វើការបណ្តុះបណ្តាលដល់និស្សិត ដែលជាមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ។